# រឿង ហង្សនិងអណ្តើក

គូរដោយ គិម សុគន្ធ



# បុព្វកថា

******

ប្រភេទសៀវភៅរឿងព្រេងនិទានខ្មែរដោយរូបភាពសំរាប់កុមារ បានរៀបរៀងឡើងក្នុងគោលបំនង:

- ធ្វើអោយកុមារមានសេចក្តីសប្បាយរីករាយ
- ជួយដល់ការលូតលាស់ផ្នែកស្មារតី និងអប់រំបញ្ញារបស់កុមារ
- អោយកុមារស្គាល់វប្បធម៌របស់ខ្មែរ
- ជួយដល់ឪពុកម្តាយ រឺលោកគ្រូ អ្នកគ្រូ ក្នុងការនិទានរឿង សំរាប់កុមារ ។

យើងខ្ញុំរង់ចាំទទួលនូវការផ្តល់មតិកែលំអពីមិត្តអ្នកអានទាំងអស់ ដោយសេចក្តីសោមនស្សរីករាយជាទីបំផុត ។

សូមអរគុណ

# រឿង ហង្ស និង អណ្តើក



គូរដោយ គីម សុគន្ធ

អ្នកបោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត (SVA)



មានហង្សមួយគូតែងនាំគ្នាទៅលេងទឹកស្រះមួយ ហើយយកអណ្ដើកធ្វើជាសំលាញ់ ។ រាល់ពេល ហង្សមកលេងទឹក អណ្ដើកតែងវារចេញមកចរចា ប្រាស្រ័យនឹងគ្នា ។





លុះនៅយូរទៅ ទឹកស្រះរីងខះមិនអាចរស់នៅបាន អណ្តើកក៏និយាយនឹងហង្សជាមិត្តថា "សំលាញ់អើយ! ខ្ញុំរស់នៅក្នុងស្រះនេះតទៅទៀតពុំបានឡើយ ព្រោះគ្មានទឹក សូមសំលាញ់ជួយគិតខ្ញុំផង" ។

ឯហង្សទាំងគូក៏ឆ្លើយថា "បើអ៊ីចឹង! យើងនាំបងអណ្តើកទៅនៅស្រះឈូកធំមួយ ឯព្រៃហិមពាន្តវិញចុះ ចំពោះការធ្វើដំណើរ យើងទាំងពីរជាភ្នាក់ងារនាំបងទៅដោយផ្លូវអាកាស" ។ អណ្តើកបានស្តាប់ហើយ ក៏ព្រមតាម ។



ពេលនោះ ហង្សបានអោយអណ្តើកខាំឈើស្នែងមួយ
ហើយហាមអណ្តើកថា « ចូរសំលាញ់រក្សាមាត់អោយជិត



បើឃើញអ្វី ៗ បានលឺសព្ទអ្វី កុំបើកមាត់សួរវិនិយាយឡើយ ព្រោះការដើរដោយអាកាសនោះក្រលំបាកណាស់ តែភ្លាត់មាត់កាលណាក៏វិនាសក្នុងកាលនោះហើយ។ ចូរសំលាញ់ប្រយ័ត្នមាត់អោយមែនទែន » ។ ហង្សទាំងពីរហាមអណ្តើកហើយក៏ខាំពាំឈើស្នែង ហើរហោះផ្លោះឡើងលើអាកាសវេហាស៍តំរង់ទៅព្រៃហិមពាន្តនាឧត្តរទិស ។





លុះមកដល់កណ្ដាលនគរពារាណសី បណ្ដាក្មេង
ទាំងឡាយបានឃើញហង្សហើរពាំនាំអណ្ដើកដូចនេះ
វាក៏បង្ហូកហៅគ្នា គឹកកងរំពងឡើងទាំងស្រែកប្រាប់
ថា “វ៉ុយ! គ្នាយើង ឯងមើលហង្សវាពាំអណ្ដើកនោះ
ប្រហែលយកទៅស៊ីឯសំបុកវាហើយ” ។





ឯអណ្ដើកបានលឺពាក្យកូនក្មេងស្រែកថាដូចនេះ ក៏ខឹងនឹងកូនក្មេងយ៉ាងខ្លាំង ។



វាគិតថា «ក្មេងទាំងនេះ មាក់ងាយអញពេញទីតែម្ដង ! មិនសមសោះ ! ហង្សជាសំលាញ់យកអាសាយើងជាមិត្ត ខំនាំយើងយកទៅទុកឯមហាស្រះឯណោះ វាបែរជាមកនាំគ្នាថា ហង្សពាំអញទៅស៊ីវិញ » ។



អណ្ដើកគិតហើយកើតទោសោនឹងពួកក្មេងៗ ហាមាត់ឡើងនឹងជេរក្មេងទាំងនោះ ។ គ្រាន់តែហាមាត់កាលណា វាក៏របូតមាត់ចេញពីឈើស្នែងធ្លាក់ចុះមកដីភ្លាម ។





អណ្ដើកមិនបានស្ដាប់តាមដំបូន្មានសំលាញ់ទាំង
ពីរបណ្ដាលអោយជួបគ្រោះអន្ដរាយដល់ក្ដីស្លាប់ ។





កាលបើអណ្ដើករបូតមាត់ធ្លាក់ពីឈើស្នែងហើយ ហង្សទាំងពីរក៏នាំគ្នាចោលឈើស្នែងនោះ ហើយពោលថា "អណ្ដើកអើយ ឯងមិនស្ដាប់តាមយើងហាម ទើបបាននូវក្ដីវិនាសយ៉ាងនេះឯង" ។

ថាហើយក៏នាំគ្នាហើរទៅកាន់លំនៅនៃអាត្មា ៕

ចប់



# រឿង ហង្ស និង អណ្តើក

និពន្ធនិងរៀបរៀងដកស្រង់ពីសៀវភៅគតិលោកភាគ៧

គូររូបដោយ លោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០០២

